# II-រាជរដ្ឋាភិបាល

## ១-អនុក្រឹត្យ

### អនុក្រឹត្យលេខ ៧៥ អនក្រ.បក

### ស្តីពីការផ្ទេរឥណទាន

✧✧✧✧✧

### រាជរដ្ឋាភិបាល

-បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រឹត្យរបស់ព្រះករុណាព្រះបាទសម្តេចព្រះ នរោត្តម សីហនុ ព្រះមហាក្សត្រ នៃព្រះរាជាណាចក្រកម្ពុជា ចុះថ្ងៃទី០១ ខែវិច្ឆិកា ឆ្នាំ១៩៩៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលកម្ពុជា

-បានឃើញច្បាប់ស្តីការរៀបចំនិងការប្រព្រឹត្តិទៅរបស់គណៈរដ្ឋមន្ត្រីដែលប្រកាសអោយប្រើដោយព្រះរាជក្រម ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤

-បានឃើញព្រះរាជក្រឹត្យ នស/រកត/១០៩៤/៨៣ ចុះថ្ងៃទី២៤ ខែតុលា ឆ្នាំ១៩៩៤ ស្តីពីការកែសំរួលសមាសភាពរាជរដ្ឋាភិបាល

-បានឃើញព្រះរាជក្រឹត្យលេខ ស.រកត ០៨៩៧.១៤៧ ចុះថ្ងៃទី៧ ខែសីហា ឆ្នាំ១៩៩៧ ស្តីពីការកែសំរួលសមាសភាពរាជរដ្ឋាភិបាល

-បានឃើញច្បាប់ស្តីពីការបង្កើតក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ដែលប្រកាសអោយប្រើដោយព្រះរាជក្រមលេខ នស/រកម/០១៩៦/.. ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦

-បានឃើញច្បាប់ស្តីពីប្រព័ន្ធហិរញ្ញវត្ថុ ដែលប្រកាសអោយប្រើដោយព្រះរាជក្រមលេខ០១ នស៩៣ ចុះថ្ងៃទី២៨ ខែធ្នូ ឆ្នាំ១៩៩៣

-បានឃើញច្បាប់ស្តីពីហិរញ្ញវត្ថុ សំរាប់ការគ្រប់គ្រងឆ្នាំ១៩៩៧ ដែលប្រកាសអោយប្រើដោយព្រះរាជក្រមលេខ នស/រកម/១២៩៦/៣៧ ចុះថ្ងៃទី៣១ ខែធ្នូ ឆ្នាំ១៩៩៦

-បានឃើញអនុក្រឹត្យលេខ ០៩ អនក្រ.បក ចុះថ្ងៃទី២៧ ខែមករា ឆ្នាំ១៩៩៧ របស់រាជរដ្ឋាភិបាល ស្តីពីការបែងចែកឥណទានផ្ទៃក្នុងជំពូកនៃច្បាប់ស្តីពីហិរញ្ញវត្ថុ សំរាប់ការគ្រប់គ្រងឆ្នាំ១៩៩៧

-បានឃើញប្រកាសលេខ ០១ ប្រ.សហវ ចុះថ្ងៃទី៧ ខែមករា ឆ្នាំ១៩៩៤ របស់ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ស្តីពីចំណាត់ថ្នាក់ចំណូល និងចំណាយថវិកាតាមប្រភេទជំពូក ប្រការ កថាខ័ណ្ឌ វាក្យខ័ណ្ឌ នៃច្បាប់ហិរញ្ញវត្ថុ សំរាប់ការគ្រប់គ្រង ឆ្នាំ១៩៩៤ និងប្រកាស ស្តីពីការកែប្រែ និងបំពេញបន្ថែមជាបន្តបន្ទាប់មានៈ លេខ ០២២ ប្រ.សហវ ចុះថ្ងៃទី៧ ខែមីនា ឆ្នាំ១៩៩៤ លេខ ០០៣ ប្រ.សហវ ចុះថ្ងៃទី២៣ ខែមករា ឆ្នាំ១៩៩៥ លេខ ៣២៣ ប្រក.សហវ.ថ ចុះថ្ងៃទី០២ ខែកញ្ញា ឆ្នាំ១៩៩៥ លេខ៣៣៦ ប្រក.សហវ.ថ ចុះថ្ងៃទី១២ ខែតុលា ឆ្នាំ១៩៩៥ លេខ ០៧១ ប្រក.សហវ.ថ ចុះថ្ងៃទី៥ ខែមេសា ឆ្នាំ១៩៩៦ និងលេខ ៨០១ សហវ.ថ ចុះថ្ងៃទី១១ ខែធ្នូ ឆ្នាំ១៩៩៦

-តាមសំណើរបស់ឯកឧត្តមទេសរដ្ឋមន្ត្រី និងជារដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ

**សំរេច**

មាត្រា ១.- ត្រូវបានអនុញ្ញាតអោយផ្ទេរឥណទានពីជំពូក ៤១(ចំណាយឥតគ្រោងទុក) នៃ ថវិការដ្ឋចំនួន ១.៥០០ លានរៀល(មួយពាន់ប្រាំរយលានរៀលគត់) មកជំពូក ១១ (ចំណាយដំណើរការរដ្ឋបាល សំភារៈ និងជួសជុលតូច) ចំនួន ១.០០០ លានរៀល (មួយពាន់លានរៀល)ជំពូក ៣០ (អន្តរាគមន៍ក្នុងវិស័យសេដ្ឋកិច្ច) ចំនួន ៥០០ លានរៀល (ប្រាំរយលានរៀល) ក្នុងវង្វង់ថវិកា របស់ទីស្តីការគណៈរដ្ឋមន្ត្រី សំរាប់ការគ្រប់គ្រងឆ្នាំ១៩៩៧ ។

មាត្រា ២.- ឥណទានក្នុងមាត្រា ១ ត្រូវបានអនុញ្ញាតអោយប្រើប្រាស់ សំរាប់បំពេញតំរូវការចំណាយជូនរាជរដ្ឋាភិបាល និងអាជ្ញាធរជាតិប្រយុទ្ធប្រឆាំងគ្រឿងញៀន ។

មាត្រា ៣.- សហរដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ត្រូវទទួលបន្ទុកអនុវត្តអនុក្រឹត្យនេះ ចាប់ពីថ្ងៃចុះហត្ថលេខានេះតទៅ ។

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី១៨ ខែវិច្ឆិកា ឆ្នាំ១៩៩៧

នាយករដ្ឋមន្ត្រីទី១ នាយករដ្ឋមន្ត្រីទី២

ហត្ថលេខា និងត្រា

អ៊ឹង ហួត ហ៊ុន សែន